ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិធីប្រកាស សាលាបឋមសិក្សាចតុមុខ ជាសាលារៀនគំរូ ក្នុងអនុវត្តសកម្មភាពសុខភាពសិក្សាគ្រប់ជ្រុងជ្រោយ

នៅឆ្នាំសិក្សា១៩៧៩-១៩៨០ សាលាបឋមសិក្សាចតុមុខ ជាសាលារៀនដំបូងគេ ដែលបានបើកបវេសនកាលជាប្រវត្តិសាស្ត្រ ដើម្បីប្រមូលសិស្សានុសិស្សចូលរៀនវិញ ក្រោយថ្ងៃជ័យជំនះ ៧ មករា ១៩៧៩។ ក្នុងឆ្នាំសិក្សា ២០២០-២០២១ ក្រសួងអប់រំ យុវជន និងកីឡាបានជ្រើសរើសសាលារៀននេះ ដើម្បីអនុវត្តសកម្មភាពសុខភាពសិក្សាគ្រប់ជ្រុងជ្រោយមុនគេ ស្របតាមយុទ្ធសាស្ត្រទាំងប្រាំបួន ដែលមានចែងក្នុងគោលនយោបាយជាតិស្តីពីសុខភាពសិក្សា។

ពិធីប្រកាស សាលាបឋមសិក្សាចតុមុខជាសាលារៀនគំរូ ក្នុងការអនុវត្តសកម្មភាពសុខភាពសិក្សាគ្រប់ជ្រុងជ្រោយ នឹងប្រារព្ធឡើងនៅថ្ងៃពុធ ៦រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង៨ព្រឹក ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង អង្គភាពពាក់ព័ន្ធ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តំណាងក្រសួងសុខាភិបាល អាជ្ញាធរដែនដី ដៃគូអភិវឌ្ឍន៍ វិស័យឯកជន តំណាងមាតាបិតា និងតំណាងសិស្សានុសិស្ស សរុបប្រមាណ ១០០ នាក់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកសារព័ត៌មាន និងសាធារណជន មេត្តាជ្រាប និងចូលរួមគាំទ្រការអនុវត្តសកម្មភាពសុខភាពសិក្សាគ្រប់ជ្រុងជ្រោយនៅតាមគ្រឹះស្ថានសិក្សា ព្រមទាំងចូលរួមអនុវត្តទស្សនាទាន **"គន្លងជីវិតថ្មីក្នុងវិស័យអប់រំ"** ទាំងអស់គ្នាឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ថ្ងៃ ចន្ទ ៥រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០២១

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh